ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ ៤៧៥ អយក.ប្រក

# ប្រកាស

## ស្ដីពី ការបើកសាលាបឋមសិក្សា ស្ទឹងសាមគ្គី ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា មាស គង់

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.ប.កចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្ដីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតស្នើសុំរបស់សហគមន៍ប្រចាំភូមិស្រះសំបួរ និងភូមិអង្គទង ឃុំ ពង្រ ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០២ និង ចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ធំ លេខ ១០៦០ អយក.កធ.រប. ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២

-តាមយោបល់ឯកភាពរបស់ នាយកដ្ឋានបឋមសិក្សា

## សំរេច

**ប្រការ១** : បើកសាលាបឋមសិក្សា **ស្ទឹងសាមគ្គី** ជាឧបសម្ព័ន្ធរបស់សាលាបឋមសិក្សា **មាស គង់** ដែលមានទីតាំងស្ថិតនៅភូមិ **ស្រះសំបួរ** ឃុំ **ពង្រ** ស្រុក **បារាយណ៍** ខេត្ត **កំពង់ធំ**ចាប់ពីឆ្នាំសិក្សា ២០០២-២០០៣ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ស្ទឹងសាមគ្គី** ត្រូវមានប្រធានក្រុម១ នាក់ ទទួលខុសត្រូវរួមជាមួយនាយកសាលាបឋមសិក្សា **មាស គង់** ។

**ប្រការ៣** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **កំពង់ធំ** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **បារាយណ៍** នាយកសាលាបឋមសិក្សា **មាស គង់** និង ប្រធានក្រុមសាលា ឧបសម្ព័ន្ធ **ស្ទឹងសាមគ្គី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣
ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

អ៊ឹម សិទ្ធី

**កន្លែងទទួល**

-ទីស្ដីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលាខេត្ត កំពង់ធំ

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៣
-កាលប្បវត្តិ-ឯកសារ នា.បស